*នេះគឺជាអត្ថបទ ដងស្រង់ ដែលខ្ញុំជួបប្រទះដោយចៃដន់  តាមអ៊ីនទែរណែត ។ អត្ថបទនេះ មាននៅលើទំព័រកាសែតជាភាសាខ្មែរ នៅកាណាដា ។*
*សូមបងប្អូនវិនិច្ឆ័យ ទៅតាមការគួរ ។*
*ក្រាក់ម៉ូ*

ការចូលរួមប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម បន្ទាប់ពីការចេញផ្សាយមក
សារព័ត៌មានខ្មែរកាណាដាទទួលបាននូវ
ការចាប់ អារម្មណ៍ពីសំណាក់ប្រិយមិត្តអ្នកអាន។ កាលពីចុងឆ្នាំ២០០៥ សារព័ត៌មាន
ខ្មែរកាណាដាបានចេញ
ផ្សាយបទយកការណ៍បន្តបន្ទាប់ស្តីពីក្រុមបងធំ ជនជាតិខ្មែរដែលបង្កចលាចល
នៅក្នុងទីក្រុងម៉ុងរេអាល់។ សារព័ត៌មានចុះផ្សាយអត្ថបទនិយាយការជួញដូរ និង
បញ្ហាសណ្តាប់ធ្នាប់សាធារណៈជាដើម។ ចំណងជើងព័ត៌មានទាំង
នោះបានរែកមុខក្រុមជនពាលាអារ៉ាសៃ និងបានអំពាវនាវដល់ប្រិយមិត្តអ្នកអានអោយសហការ
ជាមួយនឹងអាជ្ញាធរប៉ូលីស។ ការផ្សព្វផ្សាយព័ត៌មាននេះបានជះឥទ្ធិពលយ៉ាងឆាប់រហ័ស។
ភ្លាមៗនោះ
បណ្តាញក្រុមជនពាលត្រូវបានកំទេចទាំងស្រុង។